**សុន្ទរកថារបស់ ឯកឧត្តម ហូរីណូអ៊ុជិ ហ៊ីដេហ៊ីសា**
**ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា**
**ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ**
**២៤ មីនា ២០១៧**

- សូមគោរព **លោក ថន ថារិន** ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ស្ពឺ
- សូមគោរព **លោកស្រី ច័ន្ទ ខាំឃឿ** ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តរតនគិរី
- សូមគោរព **លោក អ៊ុង តុលា** ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តកណ្តាល
- សូមគោរព អស់លោក លោកស្រី!

ថ្ងៃនេះខ្ញុំមានសេចក្តីសប្បាយរីករាយ ដែលបានប្រារព្ធពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយសម្រាប់គម្រោងគូសាណូណិ។

ជំនួយទី១ មានថវិកាចំនួន ៧៥,៤១៥ដុល្លារអាមេរិក សម្រាប់គម្រោងសាងសង់អគារសិក្សា១ខ្នង នៅអនុវិទ្យាល័យស្លាបលែង ក្នុងស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ។ គម្រោងនេះ គឺជាគម្រោងទី៣៩ ដែលបានផ្តល់ជូនជាអគារសិក្សាដល់ខេត្តកំពង់ស្ពឺ ក្រោមជំនួយគូសាណូណិ។ គម្រោងនេះ ត្រូវបានរំពឹងថា នឹងកែលម្អបរិស្ថានអប់រំសម្រាប់សិស្សានុសិស្សប្រមាណជា ១,១៣៩នាក់។

ជំនួយទី២ និងទី៣ មានថវិកាចំនួន៨៣,០០០ដុល្លារអាមេរិក និងថវិកាចំនួន ៨០,៧៥០ដុល្លារអាមេរិក សម្រាប់គម្រោងសាងសង់អគារសិក្សា១ខ្នង នៅអនុវិទ្យាល័យសម្តេចឪសម្តេចម៉ែ ក្នុងក្រុងបានលុង ខេត្តរតនគិរី និងគម្រោងសាងសង់អគារសិក្សា១ខ្នងទៀត នៅសាលាមត្តេយ្យនិងបឋមសិក្សាយ៉ាដាវ ក្នុងស្រុកអូរយ៉ាដាវ ខេត្តរតនគិរី។ អគារទាំងពីរនេះ គឺជាអគារសិក្សាដំបូង ដែលបានផ្តល់ជូនដល់ខេត្តរតនគិរី ក្រោមជំនួយគូសាណូណិ។ គម្រោងទាំងនេះត្រូវបានរំពឹងថា នឹងកែលម្អបរិស្ថានអប់រំសម្រាប់សិស្សានុសិស្សប្រមាណជា ១,៨៣១នាក់ និង ៦៧៧នាក់។

ជំនួយទី៤ មានថវិកាចំនួន ៨០,២៤៤ដុល្លារអាមេរិក សម្រាប់គម្រោងសាងសង់អគារសិក្សា១ខ្នង នៅសាលាបឋមសិក្សាគគីរ ក្នុងស្រុកកៀនស្វាយ ខេត្តកណ្តាល។ នេះគឺជាអគារសិក្សាទី២៦ ដែលបានផ្តល់ជូន ដល់ខេត្តកណ្តាល ក្រោមជំនួយគូសាណូណិ។ គម្រោងនេះត្រូវបានរំពឹងថា នឹងកែលម្អបរិស្ថានអប់រំសម្រាប់សិស្សានុសិស្សប្រមាណជា ១,៣៥៦នាក់។

ជាទីបញ្ចប់ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថាគម្រោងទាំងនេះ នឹងអនុវត្តទៅដោយរលូន ហើយសំណង់និងសម្ភារៈបរិក្ខារទាំងអស់ នឹងត្រូវបានថែទាំអោយបានល្អ ដើម្បីអោយប្រជាជនអាចប្រើប្រាស់បានយូរអង្វែង និងផ្តល់អត្ថប្រយោជន៍ដល់ប្រជាជនកាន់តែច្រើនថែមទៀត។ ខ្ញុំក៏សង្ឃឹមថាគម្រោងទាំងនេះ នឹងជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាពរវាងប្រជាជនជប៉ុន និងប្រជាជនកម្ពុជា។

**សូមអរគុណ!**